អ្នកមានសិទ្ធិ និងការទទួលខុសត្រូវ ដើម្បីចូលរួមការងារគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ និងសាមគ្គីភាពក្នុងការថែរក្សាបរិស្ថានរស់នៅក្នុងសហគមន៍របស់អ្នក។



អ្នកត្រូវទទួលខុសត្រូវក្នុងការរាយការណ៍នូវព័ត៌មានហានិភ័យទាំងឡាយដែលអាចបង្កទៅជាគ្រោះមហន្តរាយ ឬពេលណាមានគ្រោះមហន្តរាយកើតឡើង !



នៅក្នុងមាត្រា ៣៦និង៣៧ បានបង្ហាញយ៉ាងច្បាស់អំពីសិទ្ធិ និងកាតព្វកិច្ចរបស់បុគ្គលគ្រប់រូប ដែលពាក់ព័ន្ធក្នុងការងារគ្រប់គ្រងគ្រោះមហន្តរាយ និងស្របតាមការណែនាំពីអាជ្ញាធរមានសមត្ថកិច្ចដូចជាគ.ជ.គ.ម។ មាត្រានេះបានទទួលស្គាល់នូវសារៈសំខាន់នៃបរិស្ថានធម្មជាតិនៅក្នុងជីវិតរស់នៅរបស់សហគមន៍អ្នក ដែលមនុស្សម្នាក់ៗមានតួនាទីក្នុងការចូលរួមកសាងភាពធន់នៅក្នុងសហគមន៍របស់ពួកគេ។

ប្រសិនអ្នកបានដឹងពីស្ថានភាពហានិភ័យ ដូចជាមុខសញ្ញាគ្រោះថ្នាក់ដែលអាចបង្កផលប៉ះពាល់ដល់សហគមន៍ អ្នកត្រូវរាយការណ៍ទៅអាជ្ញាធរមានសមត្ថកិច្ច។

បើអ្នកបានដឹងអំពីស្ថានភាពហានិភ័យដែលអាចបង្កឱ្យមានគ្រោះមហន្តរាយ ហើយមិនបានរាយការណ៍ អ្នកអាចប្រឈមមុខនឹងទោសទណ្ឌ។

ដើម្បីស្វែងយល់កាន់តែច្រើន នូវអ្វីដែលអ្នកអាចចូលរួមពាក់ព័ន្ធបានក្នុងការងារគ្រប់គ្រងគ្រោះមហន្តរាយនៅក្នុងសហគមន៍របស់អ្នក អ្នកអាចទំនាក់ទំនងជាមួយមេភូមិ ឬសមាជិកនៃក្រុមគ្រប់គ្រងគ្រោះមហន្តរាយភូមិ។




**គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (គ.ជ.គ.ម)**

អាស័យដ្ឋាន ៖ អគាររដ្ឋបាលសាធារណៈថ្មី ផ្លូវលេខ ៥១៦
សង្កាត់ទួលសង្កែ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (៨៥៥)២៣ ៨៦៤ ២៩៨
ទូរសារ : (៨៥៥)២៣ ៨៨២ ០៤៥
អ៊ីម៉េល : administration@ncdm.gov.kh
វេបសាយ : www.ncdm.gov.kh

**កាកបាទក្រហមកម្ពុជា**

អាស័យដ្ឋាន ៖ឡូត៍លេខ១៦A ផ្លូវលេខ៦៥២កែង៧០
អូរបែកក្អម សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (៨៥៥)២៣ ៨៨១ ៥១១
ទូរសារ : (៨៥៥)២៣ ៨៨១ ៥២២
អ៊ីម៉េល : info@redcross.org.kh, crc_adm@online.com.kh
វេបសាយ : www.redcross.org.kh
អ្នកអាចស្វែងរកព័ត៌មានលំអិតនៅតាមសាខាកាកបាទក្រហមកម្ពុជា
ទាំង២៥រាជធានី ខេត្ត



# ដឹងអំពីសិទ្ធិ តួនាទី និង ការទទួលខុសត្រូវរបស់អ្នក ក្នុង ការងារគ្រប់គ្រងគ្រោះមហន្តរាយ

**2017**

International Federation
of Red Cross and Red Crescent Societies

# ច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ

ច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ បានចូលជាធរមាននៅក្នុងឆ្នាំ២០១៥។ គោលបំណងច្បាប់នេះ សម្រាប់កសាងភាពធន់នៅកម្ពុជា ដោយផ្តោតការយកចិត្តទុកដាក់លើការឆ្លើយតប ការសមាហរណកម្មវិធានការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ និងអាណត្តិរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដើម្បីកំណត់នូវគោលការណ៍កាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។

**មាត្រា ២**

ច្បាប់នេះមានគោលដៅដូចតទៅ ៖

- ត្រៀមបង្ការ បន្សាំ កាត់បន្ថយគ្រោះថ្នាក់មុនពេលមានគ្រោះមហន្តរាយ ដែលបង្កដោយធម្មជាតិ ឬមនុស្ស
- ឆ្លើយតប សង្គ្រោះបន្ទាន់ក្នុងពេលមានគ្រោះមហន្តរាយ
- ស្តារឡើងវិញក្រោយពេលមានគ្រោះមហន្តរាយ



## វដ្តនៃការគ្រប់គ្រងគ្រោះមហន្តរាយ




ច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ ផ្តោតលើវដ្តនៃការគ្រប់គ្រងគ្រោះមហន្តរាយ រួមមាន ការការពារ និងកាត់បន្ថយ ការត្រៀមបង្ការ ការឆ្លើយតបនិងសង្គ្រោះបន្ទាន់ និងការស្តារឡើងវិញ (មាត្រា១០ដល់មាត្រា១៣)

## ជំពូកទី៦ ÷ សិទ្ធិ និងកាតព្វកិច្ច

ទទួលស្គាល់ថា សហគមន៍ទាំងអស់មិនត្រឹមតែទទួលរងផលប៉ះពាល់ដោយគ្រោះមហន្តរាយនោះទេ ថែមទាំងជាអ្នកឆ្លើយតបដំបូងគេ និងជាទីកន្លែងដែលមនុស្សគ្រប់រូបត្រូវអនុវត្តវិធានការដើម្បីធានាថាសហគមន៍មានភាពធន់ ក៏ដូចជានៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ ដែលចែងអំពីសិទ្ធិ និងកាតព្វកិច្ចរបស់ប្រជាពលរដ្ឋកម្ពុជាក្នុងការងារគ្រប់គ្រងគ្រោះមហន្តរាយ។ សិទ្ធិទាំងនេះឆ្លុះបញ្ចាំងស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដូចជា ការគោរពសិទ្ធិមនុស្ស (មាត្រា៣១) សិទ្ធិរស់រានមានជីវិត មានសេរីភាព និងមានសន្តិសុខផ្ទាល់ខ្លួន (មាត្រា៣២) និងសេរីភាពបញ្ចេញមតិរបស់ខ្លួន (មាត្រា៤១)



**អ្នកមានសិទ្ធិរស់រានមានជីវិត ការការពារសេចក្តីថ្លៃថ្នូ និងទ្រព្យសម្បត្តិ!**

**អ្នកមានសិទ្ធិទទួលជំនួយសង្គ្រោះ!**



**អ្នកមានសិទ្ធិទទួលបាននូវព័ត៌មាន និងចំណេះដឹង!**

នៅក្នុងមាត្រា៣៥ បានចែងថា

បុគ្គលគ្រប់រូបមានសិទ្ធិទទួលបានការការពារអាយុជីវិត សេចក្តីថ្លៃថ្នូរ ទ្រព្យសម្បត្តិ និងជំនួយសង្គ្រោះ នៅក្នុងពេលមានគ្រោះមហន្តរាយ។

បុគ្គលគ្រប់រូបមានសិទ្ធិទទួលបាននូវព័ត៌មានស្តីពីមុខសញ្ញាគ្រោះថ្នាក់ ភាពងាយរងគ្រោះ ហានិភ័យ វិធីសាស្ត្របច្ចេកទេសសម្រាប់ការពារខ្លួន និងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ការត្រៀមបង្ការ ការឆ្លើយតបគ្រោះមហន្តរាយ និងស្តារឡើងវិញ។

ពលរដ្ឋខ្មែរគ្រប់រូបមានសិទ្ធិទទួលបានធនធានសម្រាប់អនុវត្តវិធានការការពារ និងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ដើម្បីស្តារជីវភាពរស់នៅឡើងវិញ ក្រោយគ្រោះមហន្តរាយ។

មាត្រា ៣៩

រដ្ឋត្រូវមានថវិកា និងធនធានបម្រុងសមស្រប សម្រាប់ធានាការងារគ្រប់គ្រងគ្រោះមហន្តរាយ។